**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
លេខ: ០០៥/២៣.ក..... អអរ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផល នៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដឹកនាំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការនាយករដ្ឋមន្ត្រី (វិមានសន្តិភាព) នាព្រឹកថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ នេះ ដើម្បីពិភាក្សានិងអនុម័តរបៀបវារៈចំនួន ៤ ដូចខាងក្រោម៖

**១- សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពី ការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

សេចក្តីព្រាងព្រះរាជក្រឹត្យនេះ មាន**៦ជំពូក** និង**២២មាត្រា** និងបានកំណត់អំពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីជាយន្តការបំពេញបន្ថែមឱ្យប្រព័ន្ធដោះស្រាយវិវាទនៅព្រះរាជាណាចក្រកម្ពុជា សំដៅលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពឆាប់រហ័ស នៃការដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួលផ្សះផ្សាក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំណងជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្តី បង្វិតការដោះស្រាយវិវាទឱ្យកាន់តែកៀកប្រជាពលរដ្ឋនៅមូលដ្ឋាន ធានានូវភាពសុខដុមរមនា និងយុត្តិធម៌ក្នុងសង្គមជាតិ។ រាល់ដំណោះស្រាយវិវាទត្រូវតែគោរពតាមឆន្ទៈយល់ព្រមដោយសេរី និងដោយស្ម័គ្រចិត្តពីភាគីវិវាទ។ **អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** សរសេរកាត់ថា **អ.ជ.ក.** នឹងត្រូវបង្កើតឡើងដើម្បីដោះស្រាយក្រៅប្រព័ន្ធតុលាការ នូវវិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀត តាមរយៈការសម្រុះសម្រួលផ្សះផ្សាដោយផ្អែកតាមកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ឬតាមការស្នើសុំរបស់ភាគីវិវាទ ឬដែលភាគីវិវាទយល់ព្រមទទួលយកយន្តការសម្រុះសម្រួលផ្សះផ្សានេះ លើកលែងតែវិវាទដែលមិនអាចជាកម្មវត្ថុ នៃការសម្រុះសម្រួលផ្សះផ្សាតាមកំណត់របស់ច្បាប់។ **អ.ជ.ក.** មានសមាសភាព ឧបនាយករដ្ឋមន្ត្រី **១រូប** ជាប្រធាន អមដោយអនុប្រធាន **៤រូប** (ទេសរដ្ឋមន្ត្រី **១រូប** រដ្ឋមន្ត្រីក្រសួងអធិការកិច្ច រដ្ឋលេខាធិការក្រសួងមហាផ្ទៃ **១រូប** និងរដ្ឋលេខាធិការក្រសួងយុត្តិធម៌ **១រូប**) និងមានសមាជិកមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ដោយមាន **អគ្គលេខាធិការដ្ឋាន** មួយជាសេនាធិការ។

ក្នុងសេចក្តីថ្លែងហេតុជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានគូសបញ្ជាក់ថា **ព្រះរាជក្រឹត្យ** នេះ នឹងក្លាយជាក្របខណ្ឌគតិយុត្តមួយដ៏សំខាន់សម្រាប់ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាព នៃការសម្រុះសម្រួលដោះស្រាយបញ្ហាវិវាទរបស់ប្រជាពលរដ្ឋ ជាពិសេសវិវាទនៅមូលដ្ឋានឱ្យបានកាន់តែឆាប់រហ័ស និងប្រកបដោយជំនឿចិត្ត។ ឯកឧត្តម បានគោរពស្នើសុំ **សម្តេចធិបតី** ចាប់ផ្តើមធ្វើយុទ្ធនាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាបន្ទាន់ បន្ទាប់ពីត្រូវបានបង្កើតចេញជារូបរាង។

ក្នុងដំណើរការពិនិត្យ និងពិភាក្សា សេចក្តីព្រាងព្រះរាជក្រឹត្យនេះដែរ **សម្តេចធិបតី** បានគូសបញ្ជាក់ថា យន្តការនេះមិនមែនជាការជំនួសប្រព័ន្ធតុលាការទេ ប៉ុន្តែជាជម្រើសបន្ថែម និងដោយស្ម័គ្រចិត្តជូនប្រជាពលរដ្ឋ ពុំមានការបង្ខិតបង្ខំ ដើម្បីនាំមកនូវសុខដុមនីយកម្មក្នុងសង្គមខ្មែរ។ **សម្តេចធិបតី** ក៏បានសង្កត់ធ្ងន់លើសារសំខាន់នៃការធ្វើយុទ្ធនាការផ្សព្វផ្សាយជូនប្រជាពលរដ្ឋដើម្បីឱ្យពួកគាត់យល់ច្បាស់អំពីយន្តការថ្មីនេះ និងបានសម្រេចប្រគល់ភារកិច្ចជូនទីស្តីការគណៈរដ្ឋមន្ត្រី សហការជាមួយក្រសួងយុត្តិធម៌ ក្នុងការរៀបចំនីតិវិធីបន្តដើម្បីបញ្ជូន **សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពី ការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ទូលថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីទ្រង់ពិនិត្យ និងឡាយព្រះហស្តលេខាប្រកាសឱ្យប្រើទុកជាការប្រញាប់។

## ២- សេចក្តីព្រាងច្បាប់ ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៤

សេចក្តីព្រាងច្បាប់នេះមាន **៥ជំពូក** និង**១៤មាត្រា** និងត្រូវបានរៀបចំឡើងក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលដឹកនាំដោយ គណបក្សប្រជាជនកម្ពុជា បន្តទទួលបាននូវទំនុកចិត្តដ៏ច្រើនលើសលប់ចេញពីឆន្ទៈរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស ក្នុងការដឹកនាំប្រទេសជាតិសម្រាប់រយៈពេល ៥ ឆ្នាំបន្តទៀត។ នៅឆ្នាំ២០២៤ រាជរដ្ឋាភិបាលគ្រោងចំណាយថវិកាសរុបចំនួន **៣៨ ៨២៩ ប៊ីលានរៀល** ក្នុងនោះ ថវិកាចំណាយនៅថ្នាក់ជាតិ ឆ្នាំ២០២៤ មានចំនួន **៣៤ ៤៩៧ ប៊ីលានរៀល** ត្រូវជា **២៤,១៣%** នៃ **ផ.ស.ស.** ថយចុះ **៥,៨%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២៣ និងចំណាយនៅថ្នាក់ក្រោមជាតិ មានចំនួន **៤ ៣៣២ ប៊ីលានរៀល** មានសមាមាត្រស្មើនឹង **១១,៧%** នៃចំណាយថវិការដ្ឋសរុប ត្រូវជា **៣,០៣%** នៃ **ផ.ស.ស.** កើនឡើង **៦,៦%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៣។ ជាការកត់សម្គាល់ សម្រាប់ឆ្នាំ២០២៤ វិស័យសង្គមកិច្ចនៅតែជាអទិភាពក្នុងការចំណាយ ដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ថវិកាឆ្នាំ ២០២៤ ជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយ សម្រាប់ឱ្យរាជរដ្ឋាភិបាលអាចឆ្លើយតបនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង ទាំងក្នុង និងក្រៅប្រទេស ដែលត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវជំហាននៃការអនុវត្ត គោលជំហរពង្រឹងប្រសិទ្ធភាពថវិកា ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ **មនុស្ស** សមត្ថភាពស្ថាប័ន ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់រចនាសម្ព័ន្ធ ដែលមានអភិបាលកិច្ចជាស្នូល ហើយអាចប្រសិទ្ធនាមបានថា **ជាថវិកាយុទ្ធសាស្ត្រ នៃការរក្សាសមិទ្ធផលដែលសម្រេចបានដោយលំបាក និងការបន្តបុកគ្រឹះថ្មីៗ ឆ្ពោះទៅសម្រេចគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។**

ក្នុងដំណើរការពិនិត្យ និងពិភាក្សា សេចក្តីព្រាងច្បាប់ ស្តីពី **ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៤** **សម្តេចធិបតី** មានប្រសាសន៍ថាក្របខណ្ឌថវិកាឆ្នាំ២០២៤ ជាកត្តាកំណត់ នៃភាពជោគជ័យរបស់រាជរដ្ឋាភិបាល និងបានស្នើស្ថាប័នទាំងអស់យកទៅអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយ **សម្តេចធិបតី** បានចាត់ទុកឆ្នាំ២០២៤ ជាឆ្នាំសម្រាប់វាយតម្លៃអំពីការចំណាយរបស់រាជរដ្ឋាភិបាល ឱ្យចំគោលដៅ និងមានប្រសិទ្ធភាពខ្ពស់។

## ៣- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២២

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២២ មាន **៣ជំពូក** និង **២២មាត្រា**។ ថវិកាឆ្នាំ២០២២ ត្រូវបានគិតគូរៀបចំ និងអនុវត្តដោយតម្រង់ការប្រើប្រាស់ធនធាន លើការបន្តប្រយុទ្ធ និងការកសាងសមត្ថភាពរស់នៅជាមួយជំងឺកូវីដ-19 តាមគន្លងប្រក្រតីភាពថ្មី ក៏ដូចជាការទ្រទ្រង់ដល់និរន្តរភាព នៃប្រតិបត្តិការរបស់រដ្ឋមិនឱ្យរាំងស្ទះ ជាពិសេសការស្តារជីវភាពប្រជាជន និងការស្តារកិច្ចអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជាឡើងវិញ ក៏ដូចជាសម្រេចឱ្យបាននូវនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣។ នៅឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជា បានងើបឡើងវិញក្នុងអត្រា **៥,២%** ដោយរក្សាបានស្ថិរភាព នៃតម្រូវការសាកល ល្អជាងការរំពឹងទុក បើទោះបីជាទទួលរងផលប៉ះពាល់ពីសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែនយ៉ាងណាក្តី។ ការងើបឡើងវិញ នៃសេដ្ឋកិច្ចកម្ពុជា បានឆ្លុះបញ្ចាំងតាមរយៈស្ថានភាពល្អប្រសើរ នៃវិស័យបម្រើឱ្យការនាំចេញ ជាពិសេសអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ។ **ផ.ស.ស.** សម្រាប់មនុស្សម្នាក់ៗ បានកើនឡើងពី **១ ៦៥៩ ដុល្លារអាមេរិក** ក្នុងឆ្នាំ២០២១ ដល់ប្រមាណ **១ ៧៨៨ ដុល្លារអាមេរិក** ក្នុងឆ្នាំ២០២២។

សេចក្តីព្រាងច្បាប់បានឱ្យដឹងថានៅឆ្នាំ២០២២ ចំណូលថវិការដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អនុវត្តបានចំនួន **៣៧ ២៦៤ ៧៩១,៧ លានរៀល** ស្មើនឹង **៣០,៨០%** នៃ **ផ.ស.ស.** ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **៦,២%**។ ចំណែកការអនុវត្តចំណាយវិញ នៅឆ្នាំ២០២២ ការចំណាយថវិការដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានចំនួន **៣២ ៣៧៥ ៨៦៤,៤ លានរៀល** ស្មើនឹង **២៦,៧៦%** នៃ **ផ.ស.ស.** ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន ៨,៨%។

## ៤- សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើសេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូ សេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃអេមីរ៉ាតអារ៉ាប់រួម

សេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃអេមីរ៉ាតអារ៉ាប់រួម ត្រូវបានរៀបចំឡើងចំនួន **៣មាត្រា**។ កិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខា នៅព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ រវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៃប្រទេសទាំងពីរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈកិច្ចព្រមព្រៀងនេះ កម្ពុជានឹងមានលទ្ធភាព ក្នុងការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញទៅកាន់ប្រទេសអេមីរ៉ាតអារ៉ាប់រួម ទាក់ទាញទីផ្សារពីតំបន់មជ្ឈិមបូព៌ា និង

អាហ្វ្រិកខាងជើង ព្រមទាំងជួយជំរុញនិងទាក់ទាញក្រុមហ៊ុនវិនិយោគ និងភ្ញៀវទេសចរពីអេមីរ៉ាតអារ៉ាប់រួម មកកាន់កម្ពុជាផងដែរ។

**បញ្ហាផ្សេងៗ៖**

- **សម្តេចធិបតី** បានថ្លែងអំណរគុណគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងស្ថាប័នពាក់ព័ន្ធ ដែលបានអន្តរាគមទាន់ពេលវេលា ក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋពីគ្រោះទឹកជំនន់ និងបានណែនាំឱ្យបន្តត្រៀមលក្ខណៈឱ្យបានគ្រប់ពេលវេលា។
- **សម្តេចធិបតី** បានណែនាំឱ្យស្ថាប័នពាក់ព័ន្ធ ស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធនានាដែលរងការខូចខាតដោយទឹកជំនន់ និងផ្តល់ស្រូវពូជដល់ប្រជាកសិករដើម្បីចាប់ផ្តើមការដាំដុះឡើងវិញ។
- **សម្តេចធិបតី** ក៏បានណែនាំឱ្យស្ថាប័នពាក់ព័ន្ធ សិក្សាឱ្យបានល្អិតល្អន់ដើម្បីបញ្ចៀសផលប៉ះពាល់ដោយទឹកជំនន់ទៅថ្ងៃអនាគត នៅតំបន់ណាដែលអាចកាត់បន្ថយ ឬបញ្ចៀសបាន។
- **សម្តេចធិបតី** បានណែនាំឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ បង្កើនសកម្មភាពទាក់ទាញទេសចរណ៍ ជាពិសេសពង្រឹងការគ្រប់គ្រងតំបន់អង្គរឱ្យបានកាន់តែល្អប្រសើរ។
- **សម្តេចធិបតី** ណែនាំឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រៀបចំពិធីបុណ្យឯករាជ្យជាតិ និងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ឱ្យបានអធិកអធម ដើម្បីបង្កការសប្បាយរីករាយដល់ប្រជាពលរដ្ឋ ប្រកបដោយសន្តិសុខ និងសុវត្ថិភាពល្អ។

ថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**